# សេចក្ដីសម្រេច

## ស្ដីពីការកំណត់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី សម្រាប់ការស្នើសុំភ្ជាប់ចរន្តអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## អាជ្ញាធរអគ្គិសនីកម្ពុជា

- អនុវត្តតាមការកំណត់របស់ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- យោងបទប្បញ្ញត្តិស្ដីពីលក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាក្រកម្ពុជា ដែលបានអនុម័តដោយសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី១៤ នាថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៣
- យោងកំណត់បង្ហាញរបស់នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃ លេខ១០៦-១០-ហត ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១០ ស្ដីពីការកំណត់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនីសម្រាប់ការស្នើសុំភ្ជាប់ចរន្តអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញតម្រូវការចាំបាច់ក្នុងការកំណត់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនីឱ្យមានលក្ខណៈឯកភាពនៅទូទាំងក្នុងព្រះរាជាណាចក្រកម្ពុជា
- យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជាលើកទី១៩៤ នាថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១០

## សម្រេច

### ប្រការ ១ ៖

កំណត់ "ថ្លៃភ្ជាប់ចរន្ត" និង "ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី" ដែលអ្នកប្រើប្រាស់អគ្គិសនីធុនតូចនិងធុនមធ្យមត្រូវបង់ទៅឱ្យអ្នកផ្គត់ផ្គង់ នៅពេលស្នើសុំភ្ជាប់ចរន្តថ្មីពីខ្សែបណ្ដាញចែកចាយតង់ស្យុងទាបរបស់អ្នកកាន់អាជ្ញាប័ណ្ណចែកចាយណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ "ថ្លៃភ្ជាប់ចរន្ត" គឺជាការចូលរួមចំណែកវិនិយោគ របស់អ្នកប្រើប្រាស់អគ្គិសនីលើហេដ្ឋារចនាសម្ព័ន្ធភ្ជាប់ចរន្ត។ "ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី" គឺជាប្រាក់ធានាលើថ្លៃអគ្គិសនីដែលអ្នកប្រើប្រាស់បានប្រើប្រាស់មុនដោយពុំទាន់ទូទាត់។ ការកំណត់នេះ គឺសម្រាប់អ្នកកាន់អាជ្ញាប័ណ្ណក្រៅពីអគ្គិសនីកម្ពុជា។

### ប្រការ ២ ៖

អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណនៅទូទាំងព្រះរាជាណាចក្រកម្ពុជាក្រៅពីអគ្គិសនីកម្ពុជា យកថ្លៃភ្ជាប់ចរន្តពីអ្នកស្នើសុំភ្ជាប់ចរន្តធុនតូច និងធុនមធ្យម សម្រាប់ជាការចូលរួមចំណែកវិនិយោគរបស់អ្នកប្រើប្រាស់លើហេដ្ឋារចនាសម្ព័ន្ធភ្ជាប់ចរន្ត ស្របតាមការកំណត់នៃបទប្បញ្ញត្តិស្ដីពី "លក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា" តាមអត្រាដែលធ្លាប់បានកំណត់ឱ្យ

អគ្គិសនីកម្ពុជាក្នុងសេចក្តីសម្រេច លេខ០៩៧.សរ-០៥-អអក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៥ ដូចក្នុងតារាងខាងក្រោម :

<table>
<tr><th>កម្លាំងស្នើសុំប្រើប្រាស់</th><th>ថ្លៃភ្ជាប់ចរន្ត</th><th>កាតព្វកិច្ចរបស់អ្នកកាន់អាជ្ញាប័ណ្ណ</th></tr>
<tr><td colspan="2">ក-ប្រភេទ ១ហ្វា</td><td rowspan="15">អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវទទួលបន្ទុកផ្តល់សម្ភារៈ ឧបករណ៍ និងរៀបចំហេដ្ឋារចនាសម្ព័ន្ធបន្តចរន្ត រហូតដល់ក្រោមចំណុចភ្ជាប់-ផ្តាច់ “ឌីស្យុងទ័រផ្គត់ផ្គង់” ដែលអ្នកប្រើប្រាស់អាចភ្ជាប់ខ្សែរបស់ខ្លួនបន្តយកទៅប្រើប្រាស់បាន។ សម្ភារៈនិងការតម្លើងខ្សែបណ្តាញ ចាប់ពីចំណុចផ្គត់ផ្គង់នេះ រហូតដល់ទីតាំងប្រើប្រាស់ គឺជាបន្ទុករបស់អ្នកប្រើប្រាស់ផ្ទាល់។</td></tr>
<tr><td>៥ អាំពែរ</td><td>៣១,០០០ រៀល</td></tr>
<tr><td>១០ អាំពែរ</td><td>៦២,០០០ រៀល</td></tr>
<tr><td>២០ អាំពែរ</td><td>២២៨,០០០ រៀល</td></tr>
<tr><td>៣២ អាំពែរ</td><td>៤៨៤,០០០ រៀល</td></tr>
<tr><td>៦៣ អាំពែរ</td><td>១,០៩៤,៧០០ រៀល</td></tr>
<tr><td colspan="2">ខ-ប្រភេទ ៣ហ្វា</td></tr>
<tr><td>២០ អាំពែរ</td><td>៦៧៤,០០០ រៀល</td></tr>
<tr><td>៣២ អាំពែរ</td><td>១,៤៤២,៨០០ រៀល</td></tr>
<tr><td>៤០ អាំពែរ</td><td>១,៨១៦,០០០ រៀល</td></tr>
<tr><td>៦៣ អាំពែរ</td><td>៣,៣២៤,១០០ រៀល</td></tr>
<tr><td>៩០ អាំពែរ</td><td>៥,៤១៥,០០០ រៀល</td></tr>
<tr><td>១០០ អាំពែរ</td><td>៦,០២០,០០០ រៀល</td></tr>
<tr><td>១៥០ អាំពែរ</td><td>១០,១៤៥,០០០ រៀល</td></tr>
</table>

បញ្ជាក់ : **ថ្លៃភ្ជាប់ចរន្តថ្មីនេះ អនុវត្តសម្រាប់តែអ្នកសុំភ្ជាប់ចរន្តថ្មីប៉ុណ្ណោះ**។

## ប្រការ ៣ ៖

អតិថិជនប្រើប្រាស់អគ្គិសនីចាស់ ដែលបានភ្ជាប់ចរន្តប្រើប្រាស់ហើយៗកំពុងតែបន្តការប្រើប្រាស់ធម្មតា ពុំមានកាតព្វកិច្ចត្រូវបង់ថ្លៃភ្ជាប់ចរន្តដែលកំណត់ក្នុងប្រការ២ ខាងលើឡើយ ទោះជារូបភាពនៃការភ្ជាប់ចរន្តមុន មានលក្ខណៈខុសពីការកំណត់ក្នុងប្រការ២ខាងលើក៏ដោយ។

## ប្រការ ៤ ៖

ចំពោះការផ្គត់ផ្គង់អគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណណា ដែលអតិថិជនអ្នកប្រើប្រាស់អគ្គិសនីអាចទទួលអគ្គិសនីប្រើប្រាស់១ខែមុនៗពេលអ្នកកាន់អាជ្ញាប័ណ្ណ ចេញវិក្កយបត្រទារថ្លៃអគ្គិសនីដែលបានប្រើប្រាស់ អតិថិជនអ្នកប្រើប្រាស់អគ្គិសនីធុនតូច និងធុនមធ្យមត្រូវមានកាតព្វកិច្ចតម្កល់ប្រាក់កក់

ធានាថ្លៃប្រើប្រាស់អគ្គិសនីដែលប្រើប្រាស់មុនពេលទូទាត់នោះ ទៅឱ្យអ្នកផ្គត់ផ្គង់តាមការកំណត់នៅក្នុងតារាងដូចខាងក្រោម៖

| **កម្លាំងស្នើសុំប្រើប្រាស់** | **មាត្រដ្ឋានគិតប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី** | | |
|---|---|---|---|
| | **អតិថិជនលំនៅដ្ឋាន និងអគាររដ្ឋបាល** | **អតិថិជនអាជីវកម្ម និងសិប្បកម្ម** | **អតិថិជនផ្ទះជួលបរទេស សណ្ឋាគារ និងស្ថានទូត** |
| **ក-ប្រភេទ ១ហ្វា** | | | |
| ៥ អាំពែរ | ៥អាំពែ x ១៥គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៥អាំពែ x ៣០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៥អាំពែ x ៤០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ |
| ១០ អាំពែរ | ១០អាំពែ x ១៥គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ១០អាំពែ x ៣០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ១០អាំពែ x ៤០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ |
| ២០ អាំពែរ | ២០អាំពែ x ១៥គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ២០អាំពែ x ៣០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ២០អាំពែ x ៤០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ |
| ៣២ អាំពែរ | ៣២អាំពែ x ១៥គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៣២អាំពែ x ៣០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៣២អាំពែ x ៤០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ |
| ៦៣ អាំពែរ | ៦៣អាំពែ x ១៥គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៦៣អាំពែ x ៣០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៦៣អាំពែ x ៤០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ |
| **ខ-ប្រភេទ ៣ហ្វា** | | | |
| ២០ អាំពែរ | ២០អាំពែ x ៣ហ្វា x ១៥គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ២០អាំពែ x ៣ហ្វា x ៣០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ២០អាំពែ x ៣ហ្វា x ៤០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ |
| ៣២ អាំពែរ | ៣២អាំពែ x ៣ហ្វា x ១៥គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៣២អាំពែ x ៣ហ្វា x ៣០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៣២អាំពែ x ៣ហ្វា x ៤០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ |
| ៤០ អាំពែរ | ៤០អាំពែ x ៣ហ្វា x ១៥គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៤០អាំពែ x ៣ហ្វា x ៣០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៤០អាំពែ x ៣ហ្វា x ៤០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ |
| ៦៣ អាំពែរ | ៦៣អាំពែ x ៣ហ្វា x ១៥គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៦៣អាំពែ x ៣ហ្វា x ៣០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ | ៦៣អាំពែ x ៣ហ្វា x ៤០គ.វ.ម៉/ខែ x អត្រាថ្លៃលក់ |
| ៩០ អាំពែរ | ៩០អាំពែ x ៣ហ្វា x | ៩០អាំពែ x ៣ហ្វា x | ៩០អាំពែ x ៣ហ្វា x |

| | | | |
|---|---|---|---|
| | ១៥គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៣០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ៤០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ១០០ អាំពែរ | ១០០អាំពែ x ៣ហ្វា x ១៥គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ១០០អាំពែ x ៣ហ្វា x ៣០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ១០០អាំពែ x ៣ហ្វា x ៤០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ |
| ១៥០ អាំពែរ | ១៥០អាំពែ x ៣ហ្វា x ១៥គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ១៥០អាំពែ x ៣ហ្វា x ៣០គ.វ៉.ម៉/ខែ x អត្រាថ្លៃលក់ | ១៥០អាំពែ x ៣ហ្វា x ៤០គ.វ៉.ម៉/ខែ x x អត្រាថ្លៃលក់ |

បញ្ជាក់ : **“ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី” នេះ អនុវត្តសម្រាប់តែអតិថិជនស្នើសុំភ្ជាប់ចរន្តថ្មីប៉ុណ្ណោះ ។ អត្រាថ្លៃលក់ គឺជាអត្រាថ្លៃលក់ដែលកំពុងអនុវត្តនៅពេលដែលអតិថិជនស្នើសុំភ្ជាប់ចរន្ត** ។

## ប្រការ ៥ ៖

ពេលអ្នកស្នើសុំបានបង់ប្រាក់កក់រួច អ្នកកាន់អាជ្ញាប័ណ្ណត្រូវចេញប័ណ្ណប្រាក់កក់ឱ្យទៅអ្នកស្នើសុំ ដើម្បីជាភស្តុតាង និងសម្រាប់ដក “ប្រាក់កក់ធានាការប្រើប្រាស់” នេះវិញ នៅពេលបញ្ចប់កិច្ចព្រមព្រៀងភ្ជាប់ចរន្ត។ អ្នកកាន់អាជ្ញាប័ណ្ណត្រូវប្រគល់ប្រាក់កក់ធានានេះ ឱ្យទៅអ្នកប្រើប្រាស់វិញក្នុងរយៈពេល១៥ថ្ងៃយ៉ាងយូរ បន្ទាប់ពីកិច្ចព្រមព្រៀងភ្ជាប់ចរន្តបានត្រូវបញ្ចប់ និងបន្ទាប់ពីអ្នកប្រើប្រាស់បានទូទាត់បំណុលរួច ។

## ប្រការ ៦ ៖

អតិថិជនប្រើប្រាស់អគ្គិសនីចាស់ ដែលបានភ្ជាប់ចរន្តប្រើប្រាស់ហើយៗកំពុងតែបន្តការប្រើប្រាស់ធម្មតា ពុំមានកាតព្វកិច្ចត្រូវបង់ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី ដែលកំណត់ក្នុងប្រការ៤ខាងលើឡើយ ទោះជារូបភាពនៃការកម្កល់ប្រាក់ពីមុន មានលក្ខណៈខុសពីការកំណត់ក្នុងប្រការ៤ខាងលើក៏ដោយ ។

## ប្រការ ៧ ៖

ចំពោះ “ថ្លៃភ្ជាប់ចរន្ត” និង “ប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី” អនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពិនិត្យលទ្ធភាពផ្តល់ការអនុគ្រោះដល់អតិថិជនអ្នកស្នើសុំភ្ជាប់ចរន្តថ្មី ឱ្យគេអាចពន្យាពេលបង់ថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនី ឬអាចបង់រំលស់ច្រើនលើកបាន។ រយៈពេលអនុគ្រោះ និងចំនួនលើកដែលត្រូវបង់ ត្រូវកំណត់ដោយយោងទៅតាមទំនុកចិត្តរបស់អ្នកកាន់អាជ្ញាប័ណ្ណលើអតិថិជនអ្នកស្នើសុំភ្ជាប់ចរន្ត។

## ប្រការ ៨ ៖

អ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធធ្វើតេស្ត ធ្វើការផ្លាស់ប្តូរ និងធ្វើឱ្យទាន់សម័យឧបករណ៍នាឡិកាស្ទង់របស់អតិថិជនដែលភ្ជាប់ជាមួយបណ្តាញចែកចាយរបស់ខ្លួនបាន ប៉ុន្តែរាល់ការចំណាយគឺជាបន្ទុករបស់អ្នកកាន់អាជ្ញាប័ណ្ណ។ មានន័យថា រាល់ចំណាយផ្លាស់ប្តូរនាឡិកាស្ទង់ទាំងអស់ គឺជាបន្ទុករបស់អ្នកកាន់អាជ្ញាប័ណ្ណ ហើយអ្នកកាន់អាជ្ញាប័ណ្ណមិនត្រូវទាមទារឱ្យអ្នកប្រើប្រាស់បង់ថ្លៃសម្រាប់ការចំណាយខាងលើឡើយ លើកលែងតែនាឡិកាស្ទង់នោះឆេះ ខូច ឬមិនដំណើរការដោយសារមូលហេតុរបស់អ្នកប្រើប្រាស់ដែលត្រូវកំណត់ផ្សេងពីនេះ តាមបទប្បញ្ញត្តិស្តីពី "លក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា"។

**ប្រការ ៩ ៈ**

សេចក្តីសម្រេចនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅរហូតដល់មានការកែសម្រួលឡើងវិញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សេចក្តីសម្រេចទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ១០ ៈ**

អ្នកកាន់អាជ្ញាប័ណ្ណ មានភារៈកិច្ចផ្សព្វផ្សាយ និងអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចនេះ ជាមួយអតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលពាក់ព័ន្ធ និងជាមួយអ្នកស្នើសុំភ្ជាប់ចរន្តថ្មី ឱ្យមានប្រសិទ្ធភាព។

**អាជ្ញាធរអគ្គិសនីកម្ពុជា**
**ប្រធាន**

<u>ចម្លងជូន</u>៖
-ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
-សាលារាជធានីភ្នំពេញ-គ្រប់សាលាខេត្ត-ក្រុង
-គ្រប់មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល គ្រប់ខេត្ត-ក្រុង
-គ្រប់សាលាខ័ណ្ឌ-ស្រុក
-គ្រប់សាលាសង្កាត់-ឃុំ
"ដើម្បីជូនជ្រាប"
-អ្នកកាន់អាជ្ញាប័ណ្ណអគ្គិសនី ដូចប្រការ៨
"ដើម្បីអនុវត្ត"
-ឯកសារ និងកាលប្បវត្តិ